# ផ្នែកទី II

# វិធានការបង្ការគ្រប់គ្រងដំណាំ

# (IPM)

## **វិធានការចម្រុះក្នុងការគ្រប់គ្រងដំណាំ** (IPM)

វិធានការចម្រុះគ្រប់គ្រងដំណាំ (IPM) គឺជាប្រព័ន្ធគ្រប់គ្រងដំណាំដែលរួមបញ្ចូលនូវគ្រប់វិធីសាស្ត្រទាំងអស់ ដើម្បីថែរក្សា និងការពារដំណាំឱ្យដុះលូតលាស់ល្អ ទទួលបានទិន្នផលខ្ពស់ ធានាបាននូវនិរន្តរភាពផលិតកម្ម ប្រសិទ្ធភាពសេដ្ឋកិច្ច និងការពារនូវសុខុមាលភាពរបស់ប្រជាកសិករ និងបរិស្ថាន។ ចំនុចចាប់ផ្តើមរបស់កម្មវិធី IPM គឺផ្តោតជាសំខាន់ទៅលើការ កាត់បន្ថយការប្រើប្រាស់ថ្នាំកសិកម្ម ក្នុងការកម្ចាត់សមាសភាពចង្រៃ។ ទោះបីជាយ៉ាងនេះក្តី គោលការណ៍គ្រឹះក្នុងការសម្រេចចិត្ត ចំពោះការគ្រប់គ្រងដំណាំឱ្យដុះលូតលាស់ល្អ គឺការយល់ឱ្យបានកាន់តែច្បាស់លាស់អំពីប្រព័ន្ធបរិស្ថានរបស់ដំណាំ រួមទាំងសមាសភាពចង្រៃ សត្រូវធម្មជាតិ និងសមាសភាពផ្សេងៗដែលនៅជុំវិញដំណាំ។ ការចុះត្រួតពិនិត្យដំណាំទៀងទាត់ គឺជាជំហានទីមួយក្នុងការស្វែងយល់ពីប្រព័ន្ធបរិស្ថានរបស់ដំណាំ។

តាមរយៈបទពិសោធន៏ច្រើនឆ្នាំកន្លងមករបស់IPM បានបង្ហាញឱ្យដឹងថា ការគ្រប់គ្រងដំណាំឱ្យដុះលូតលាស់ល្អ អាចកាត់បន្ថយការចំណាយទុនលើមធ្យោបាយផលិតកម្ម (រួមបញ្ចូលទាំងថ្នាំកសិកម្ម) ដោយមិនធ្វើឱ្យទិន្នផលថយចុះឡើយ។ ជាការពិតណាស់ទិន្នផល តែងតែកើនឡើងនៅក្នុងចំការដែលបានដាំដុះ និងគ្រប់គ្រងតាមវិធានការ IPM ។ (គោលការណ៏ណែនាំក្នុងការដាំដុះ និងការគ្រប់គ្រងដំណាំស្ពៃក្តោប រៀបរៀងដោយកម្មវិធី IPM សហការជាមួយ FAO ខែសីហា ឆ្នាំ ២០០៨)

តាមរយៈកម្មវិធីជាតិ ស្តីពីវិធានការចម្រុះគ្រប់គ្រងដំណាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំពុងតែផ្សព្វផ្សាយណែនាំឱ្យកសិករជ្រើសរើសជាបឋមនូវ វិធានការ IPM មុននឹងឈានទៅដល់ការប្រើប្រាស់ថ្នាំកសិកម្ម ដើម្បីកម្ចាត់សមាសភាពចង្រៃ ដែលបំផ្លាញដំណាំ ។ វិធានការ IPM នេះអាចកម្ចាត់សមាសភាពចង្រៃបានដោយមានប្រសិទ្ធិភាព មិនចាំបាច់ចំណាយថវិកាច្រើន និងមិនបង្កគ្រោះថ្នាក់ដល់សុខភាព និងបរិស្ថានឡើយ។ ដោយឡែក វិធានការការពារដំណាំតាមបែបគីមី គឺជាវិធានការចុងក្រោយ ដែលត្រូវប្រើក្នុងករណីចាំបាច់បំផុត ។

កម្មវិធី IPM អនុវត្តការងារដោយផ្អែកលើគោលការណ៍គ្រឹះសំខាន់ទាំង ៤ គឺៈ

- **ដាំដំណាំឱ្យដុះលូតលាស់ល្អៈ** កសិករត្រូវចេះជ្រើសរើសពូជឱ្យបានល្អ គឺជាពូជផ្តល់ទិន្នផលខ្ពស់ ធន់នឹងការបំផ្លាញរបស់សត្វល្អិត និងជំងឺ ហើយសមស្របនឹងលក្ខខណ្ឌបរិស្ថានក្នុងតំបន់។ ក្រៅអំពីការជ្រើសរើសពូជ កសិករត្រូវអនុវត្តការរៀបចំដីឱ្យបានល្អ ប្រើប្រាស់បច្ចេកទេសដាំដុះឱ្យបានត្រឹមត្រូវ ថែទាំដំណាំឱ្យបានល្អ និងប្រើប្រាស់ជីឱ្យមានតុល្យភាព។
- **ថែរក្សាសត្វមានប្រយោជន៏ៈ** កសិករត្រូវស្វែងយល់ឱ្យបានច្បាស់អំពីប្រភេទ និងបរិមាណសត្វស៊ីដំណាំ សត្វមានប្រយោជន៏ក្នុងស្រែចំការ លក្ខណៈនៃការរស់នៅ និងការស៊ីចំណីរបស់សត្វនីមួយៗ។ តាមរយៈចំណេះដឹងទាំងនេះ កសិករនឹងមានលទ្ធភាពពិចារណាបានល្អិតល្អន់ មុននឹងចាត់វិធានការណាមួយក្នុងកិច្ចការពារដំណាំ ជាពិសេសការប្រើប្រាស់ថ្នាំកសិកម្មគីមី ។ លើសពីនេះទៀត កសិករនឹងមានលទ្ធភាពថែរក្សា

និងការពារបាននូវសត្វមានប្រយោជន៍ តាមរយៈការកាត់បន្ថយការប្រើប្រាស់ថ្នាំកសិកម្មគីមី ឬព្យាយាមជ្រើសរើសប្រភេទថ្នាំកសិកម្មគីមីដែលមានផលប៉ះពាល់តិចតួចដល់សុខភាពមនុស្ស សត្វ សត្វមានប្រយោជន៍ និង បរិស្ថាន ព្រមទាំងចេះថ្លឹងថ្លែងអំពីប្រសិទ្ធភាពសេដ្ឋកិច្ចក្នុងផលិតកម្ម។

- **ចុះពិនិត្យស្រែជាប្រចាំ:** ការចុះពិនិត្យស្រែ គឺជាការងារចាំបាច់បំផុត ដែលធ្វើឱ្យកសិករបានពិនិត្យ និងវាយតម្លៃអំពីស្ថានភាពស្រែ លក្ខណៈលូតលាស់របស់ដំណាំ ស្ថានភាពទឹក ដី ស្មៅចង្រៃ វត្ថុមានសត្វមានប្រយោជន៍ វត្ថុមានសត្វស៊ីដំណាំ និងស្ថានភាពនៃការបំផ្លាញរបស់វា នៅតាមដំណាក់កាលនីមួយៗ នៃវគ្គលូតលាស់របស់ដំណាំ។ តាមរយៈការចុះត្រួតពិនិត្យស្រែជាប្រចាំ កសិករអាចស្វែងយល់អំពីបញ្ហា ដែលកើតមាននៅក្នុងស្រែ និងចាត់វិធានការបានទាន់ពេលវេលា។
- **កសិករក្លាយទៅជាអ្នកជំនាញក្នុងផលិតកម្មដំណាំ:** បង្កើនសមត្ថភាពរបស់កសិករឱ្យចេះពិនិត្យស្ថានភាពស្រែ ចេះវិភាគ និងធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង ប្រកបដោយភាពវៃឆ្លាត តាមរយៈការ ធ្វើពិសោធន៍ ការផ្លាស់ប្តូរបច្ចេកទេសជាមួយអ្នកបច្ចេកទេស និងកសិករក្នុងតំបន់ ដើម្បីបង្កើនភាពជឿជាក់ និងពឹងផ្អែកលើខ្លួនឯង។ ជាមួយនឹងចំណេះដឹងនេះ កសិកររីករាយនឹងផ្សព្វផ្សាយនូវរាល់បច្ចេកទេសរបស់ខ្លួនដល់កសិករដទៃទៀតក្នុងសហគមន៍។

ខាងក្រោមនេះគឺជាឧទាហរណ៍ ពីរបៀបគ្រប់គ្រងសមាសភាពចង្រៃលើដំណាំស្រូវ ដោយអនុវត្តវិធានការចម្រុះគ្រប់គ្រងដំណាំ IPM ។ មានវិធីសាស្ត្រខុសគ្នាជាច្រើននៅក្នុងយុទ្ធសាស្ត្រ IPM ប៉ុន្តែវិធីសាស្ត្រដែលអាចប្រើប្រាស់បានគឺអាស្រ័យលើស្ថានភាពរបស់ដំណាំ ស្ថានភាពរបស់សមាសភាពចង្រៃ ធនធាន និងកត្តាផ្សេងៗនៅក្នុងតំបន់។

សម្រាប់ព័ត៌មានលំអិតពីវិធីសាស្ត្រ និងយុទ្ធសាស្ត្រ IPM សូមទាក់ទងទៅកាន់ កម្មវិធីជាតិស្តីពីវិធានការចម្រុះគ្រប់គ្រងដំណាំ (IPM) នៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**១.ជំងឺលើដំណាំស្រូវ**

**១.១. ជំងឺអុចត្នោត**

- ប្រើប្រាស់ពូជដែលធន់ ដើម្បីទប់ទល់នឹងការរាតត្បាតរបស់ផ្សិត
- ប្រើទឹកក្តៅ (៥៣-៥៤ អង្សាសេ) ត្រាំគ្រាប់ពូជរយៈពេល ១០-១២នាទី ដើម្បីសំអាតគ្រាប់ និងសម្លាប់មេរោគមុនពេលយកទៅដាំ
- ប្រើប្រាស់ជីឱ្យមានតុល្យភាពទៅតាមតម្រូវការនៃដំណាក់កាលលូតលាស់របស់ដំណាំស្រូវ
- គ្រប់គ្រងទឹកក្នុងស្រែឱ្យបានល្អប្រសើរ ដែលយ៉ាងហោចណាស់ ត្រូវរក្សាដីស្រែឱ្យបានសើមជានិច្ច ដើម្បីឱ្យស្រូវមានលទ្ធភាពស្រូបយកជីជាតិក្នុងដី និងអាចបែកគុម្ពបានច្រើន
- ជៀសវាងការប្រើប្រាស់ជីអាសូតក្នុងបរិមាណច្រើនហួស នៅក្នុងដំណាក់កាលដំបូងៗ ហើយខ្វះខាតនៅពេលក្រោយដែលនាំឱ្យកើតជំងឺអុចត្នោតលើគ្រាប់ស្រូវកាន់តែខ្ពស់
- អាចប្រើប្រាស់ថ្នាំសម្លាប់ផ្សិត នៅដំណាក់កាលបែកគុម្ព និងចុងដំណាក់កាលផើម ដោយពិភាក្សាជាមួយអ្នក

| | |
|---|---|
| | ឯកទេស ។ |
| ១.២. | **ជំងឺប្លាស** |
| | - ប្រើប្រាស់ពូជដែលអាចទប់ទល់នឹងការរាតត្បាតរបស់ផ្សិត ព្រោះវាមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់បំផុត<br>- ធ្វើការដាំដុះឱ្យបានដើមរដូវបន្ទាប់ពីភ្លៀងធ្លាក់ និងជៀសវាងការដាំដុះស្រូវក្រាស់ញឹកពេក<br>- ដាំដុះស្រូវជាជួរដើម្បីឱ្យពន្លឺថ្ងៃ និងខ្យល់ចេញចូលបានល្អ ដែលអាចកាត់បន្ថយការកកើតជំងឺ<br>- ជៀសវាងការប្រើប្រាស់ជីលើសកំរិត ជាពិសេសប្រភេទជីអាសូត និងជីជំរុញការលូតលាស់<br>- រំលែកជីអាសូត រួចបាចតាមដំណាក់កាលៗអាស្រ័យតាមតម្រូវការជាក់ស្តែងរបស់ដំណាំ<br>- ក្នុងករណីវាលវិធានការខាងលើមិនអាចទប់ទល់បាន ជម្រើសចុងក្រោយអាចប្រើប្រាស់ថ្នាំកម្ចាត់ផ្សិត ប្រភេទជ្រាបចូលជាប្រព័ន្ធ ដោយពិភាក្សាជាមួយអ្នកឯកទេស ។ |
| ១.៣. | **ជំងឺរលួយស្រទបស្លឹក** |
| | - លែចន្លោះគុម្ព ឬដង់ស៊ីតេដើមស្រូវឱ្យបានសមរម្យ ដោយធ្វើយ៉ាងណាកុំឱ្យកៀកគ្នា ឬណែនពេក ព្រោះវាធ្វើឱ្យជំងឺងាយកកើត និងរាលដាល<br>- ប្រើប្រាស់ជីប៉ូតាស្យូម នៅដំណាក់កាលបែកគុម្ព ដើម្បីធ្វើឱ្យជាលិការដើម និងស្លឹកស្រូវរឹងមាំ<br>- ប្រើប្រាស់កាល់ស្យូមស៊ុលផាត និងសង្កសី ដោយបាញ់លើស្លឹកនៅដំណាក់កាលបែកគុម្ព<br>- ធ្វើអនាម័យស្រែ ដោយសំអាតគល់ជញ្ជ្រាំងស្រូវដែលកើតជំងឺ និងកម្ចាត់ស្មៅចង្រៃ ដើម្បីកាត់បន្ថយការឆ្លងជំងឺ<br>- ក្នុងករណីកើតជំងឺច្រើន ប្រើថ្នាំសម្លាប់ផ្សិតលើស្លឹក នៅដំណាក់កាលផើមដោយពិភាក្សាជាមួយអ្នកឯកទេស ។ |
| ១.៤. | **ជំងឺរលាកស្រទបស្លឹក** |
| | - លែចន្លោះគុម្ព ឬដង់ស៊ីតេដើមស្រូវឱ្យបានសមរម្យដោយធ្វើយ៉ាងណាកុំឱ្យកៀកគ្នា ឬណែនពេក ព្រោះវាធ្វើឱ្យជំងឺងាយកកើត និងរាលដាល<br>- ប្រើប្រាស់ជីអាសូតឱ្យត្រូវតាមតម្រូវការរបស់ដំណាំ និងជៀសវាងការបាញ់ជីជំរុញការលូតលាស់ច្រើន<br>- ធ្វើអនាម័យស្រែដោយសំអាតគល់ជញ្ជ្រាំងស្រូវដែលកើតជំងឺ ស្មៅចង្រៃដើម្បីកាត់បន្ថយការឆ្លងជំងឺ<br>- ក្នុងករណីមានកើតជំងឺច្រើន ប្រើប្រាស់ថ្នាំសម្លាប់ផ្សិត ដោយពិភាក្សាជាមួយអ្នកឯកទេស ។ |
| ១.៥. | **ជំងឺស្រពោនស្លឹក** |
| | - ប្រើប្រាស់ពូជធន់ ដែលអាចទប់ទល់នឹងការរាតត្បាតរបស់ជំងឺ<br>- ធ្វើអនាម័យស្រែ ដូចជាកម្ចាត់ចោលនូវស្មៅចង្រៃ ចំបើង និងស្រូវដុះម្ដងដែលជាជម្រកនៃជំងឺ<br>- រក្សាទឹករាក់នៅលើថ្នាលសំណាប ដោយធ្វើចង្អូរបណ្ដោះទឹកនៅពេលមានភ្លៀងធ្លាក់ខ្លាំង<br>- ភ្ជួររាស់ដីឱ្យបានស្ងួតល្អ ក្រោយពេលប្រមូលផលស្រូវរួចដើម្បីសម្លាប់មេរោគ ប្រើប្រាស់ជីឱ្យមានតុល្យភាព ជាពិសេសជីអាសូត<br>- ត្រូវលែចន្លោះគុម្ព ឬដង់ស៊ីតេដើមឱ្យបានសមរម្យ ដោយជៀសវាងស្ទូងកៀកពេក ឬព្រោះគ្រាប់ក្រាស់ពេក ។ |

### ១.៦. ជំងឺខ្នុតស្លឹក

- ប្រើប្រាស់ពូជធន់ដែលអាចទប់ទល់នឹងការបំផ្លាញរបស់ជំងឺ
- ប្រើប្រាស់ទឹកក្តៅ ដើម្បីសំអាតគ្រាប់ពូជ និងសម្លាប់មេរោគ មុននឹងយកទៅដាំដុះ
- ប្រើប្រាស់ជីឱ្យមានតុល្យភាព ដោយជៀសវាងការប្រើប្រាស់ជីអាសូតច្រើន
- លែងទ្បោះគុម្ព ឬដង់ស៊ីតេដើមឱ្យបានសមស្របដោយជៀសវាងការដាំដុះញឹកពេក
- ភ្ជួរហាលដីបន្ទាប់ពីប្រមូលផលស្រូវរួច ដើម្បីសម្លាប់មេរោគ
- ធ្វើអនាម័យស្រែ ដូចជា កម្ចាត់ចោលនូវស្រូវដុះមូរ និងគល់ជញ្ជ្រាំង ដើម្បីបំផ្លាញប្រភពជំងឺ ធ្វើចង្អូរបណ្តោះទឹក ជាពិសេសនៅដំណាក់កាលសំណាប ។

### ១.៧. ជំងឺតឿលឿង និងជំងឺតឿរួញស្លឹក

- ប្រើប្រាស់ពូជដែលធន់នឹងភ្នាក់ងារបង្ករោគ និងភ្នាក់ងារចម្លងរោគ ( សត្វមមាចត្នោត)
- ប្រើប្រាស់ជីឱ្យមានតុល្យភាព ដោយជៀសវាងការប្រើប្រាស់ជីអាសូតច្រើន ដែលនាំឱ្យមាក់ទាញសត្វមមាចត្នោត
- ដកដើមស្រូវដែលកើតជំងឺពីក្នុងស្រែ រួចបំផ្លាញចោល
- ប្រើប្រាស់វិធានការចម្រុះដើម្បីគ្រប់គ្រងសត្វមមាចត្នោត ដែលជាភ្នាក់ងារចម្លងជំងឺ ។

### ១.៨. ជំងឺទង់គ្រោ

- ប្រើប្រាស់ពូជដែលធន់នឹងជំងឺទង់គ្រោ
- ភ្ជួររាស់ និងហាលដីបន្ទាប់ពីប្រមូលផលរួច ដើម្បីបំផ្លាញស្រូវដុះមូរ និងគល់ជញ្ជ្រាំងដែលជាជម្រកនៃភ្នាក់ងារបង្កជំងឺ
- ដកដើមស្រូវដែលកើតជំងឺ ពីក្នុងស្រែ រួចបំផ្លាញចោល ។

## ២. សត្វចង្រៃលើដំណាំស្រូវ

### ២.១. សត្វទ្រីប

- ប្រើផេះបាចលើដំណាំស្រូវដែលទទួលរងការបំផ្លាញ
- បញ្ចូលទឹកពន្លិចថ្នាលសំណាប /ស្រែ ( ស្រូវពង្រោះ)
- ប្រើស្បៃមុង ឬក្រមា ដែលមានជាតិអំបោះ ដោយជ្រលក់ទឹកឱ្យសើម រួចអូសលើថ្នាលសម្លាប់ចុះឡើងៗរួចពូតសម្លាប់សត្វទ្រីប
- បន្ទាប់ពីបញ្ចូលទឹកក្នុងស្រែរួច ប្រើប្រាស់ជីអ៊ុយរ៉េបំប៉ន ។

### ២.២. មមាចត្នោត

- គួររៀបចំថ្នាលសំណាបឱ្យនៅឆ្ងាយពីអំពូលភ្លើងអគ្គិសនី
- ប្រើពូជធន់នឹងមមាចត្នោត
- គួរដាំដុះឱ្យបានស្របពេលគ្នា

- ប្រើយុទ្ធសាស្ត្រគេច ដោយជៀសវាងការសាប /ព្រោះ /ឬស្ទូងចំពេលប្រជាករមមាចត្នោតធ្វើបម្លាស់ទីមកដល់
- ធ្វើអនាម័យស្រែ (សំអាតស្មៅចង្រៃ ទាំងនៅតាមភ្លឺ និងក្នុងស្រែ)
- ប្រើជីឱ្យបានសមស្រប និងមានតុល្យភាព (ជៀសវាងការប្រើអាសូតច្រើន)
- ក្នុងករណីមានវត្តមានមមាចត្នោតច្រើន ត្រូវពន្លិចទឹកសំណាបរួចយកស្បៃមុងអូសកម្ចាត់មមាចត្នោត
- ប្រើអន្ទាក់ភ្លើង ដើម្បីពិនិត្យប្រជាករមមាចត្នោត និងចាត់វិធានការទាន់ពេលវេលា
- ថែរក្សាសត្វមានប្រយោជន៍ ដោយកាត់បន្ថយការប្រើថ្នាំកសិកម្មគីមី
- ក្នុងករណីអនុវត្តវិធានការទាំងអស់ខាងលើមិនអាចទប់ស្កាត់បាន គួរប្រើប្រាស់ថ្នាំកសិកម្មគីមី ដោយពិភាក្សាជាមួយអ្នកជំនាញ និងជ្រើសរើសថ្នាំដែលមិនប៉ះពាល់ខ្លាំងដល់សត្វមានប្រយោជន៍ សុខភាព និងបរិស្ថាន។

### ២.៣. ដង្កូវបំពង់កាត់ស្លឹក

- ប្រើថ្នាលគោកអាចកាត់បន្ថយការបំផ្លាញដោយដង្កូវបំពង់កាត់ស្លឹក នៅដំណាក់កាលសំណាប
- បញ្ចូលទឹកក្នុងស្រែឱ្យលិចផុតបង្អែបស្លឹក រួចប្រើស្បៃអូសប្រមូលយកដង្កូវបំពង់កាត់ស្លឹកមកកម្ទេចចោល
- បង្ហូរទឹកចេញពីស្រែ (ប្រើឧបករណ៍ត្រងយកដង្កូវមកកម្ទេចចោល) ឱ្យបាន ២-៣ថ្ងៃ ទើបបញ្ចូលទឹកជាថ្មី
- ប្រើផេះបាចលើស្រែ ឬចំណែកនៃស្រែត្រង់កន្លែងដែលមានការកាត់បំផ្លាញ
- ប្រើស្លឹកស្តៅ ឬទន្ទ្រានខែត្រ បាចក្នុងស្រែត្រង់កន្លែងមានការបំផ្លាញ
- ថែរក្សាសត្វមានប្រយោជន៍ ដោយកាត់បន្ថយការប្រើប្រាស់ថ្នាំកសិកម្មគីមី
- ប្រលែងសត្វទាចូលក្នុងស្រែ ដើម្បីស៊ីដង្កូវដែលអណ្តែតលើទឹក
- ក្នុងករណីអនុវត្តវិធានការទាំងអស់ខាងលើមិនអាចទប់ស្កាត់បាន គួរប្រើប្រាស់ថ្នាំកសិកម្មគីមី ដោយពិភាក្សាជាមួយអ្នកជំនាញ និងជ្រើសរើសថ្នាំដែលមិនប៉ះពាល់ខ្លាំងដល់សត្វមានប្រយោជន៍ សុខភាព និងបរិស្ថាន។

### ២.៤. ដង្កូវស៊ីរូងដើម

- ប្រើពូជស្រូវអាយុកាលខ្លី និងប្រើពូជធន់នឹងដង្កូវស៊ីរូងដើម
- ភ្ជួរលប់គល់ជញ្ជ្រាំងភ្លាម ក្រោយពេលប្រមូលផលស្រូវដើម្បីសម្លាប់ដង្កូវ និងដឹកឿ
- គួរកម្ចាត់សំបុកពង ពេលដកសំណាប និងពេលយកសំណាបទៅស្ទូង
- ប្រើបរិមាណជីឱ្យបានសមស្រប និងមានតុល្យភាព
- ថែរក្សាសត្វមានប្រយោជន៍ ដោយកាត់បន្ថយការប្រើប្រាស់ថ្នាំកសិកម្មគីមី
- ក្នុងករណីអនុវត្តវិធានការទាំងអស់ខាងលើមិនអាចទប់ស្កាត់បាន គួរប្រើប្រាស់ថ្នាំកសិកម្មគីមី ដោយពិភាក្សាជាមួយអ្នកជំនាញ និងជ្រើសរើសថ្នាំដែលមិនប៉ះពាល់ខ្លាំងដល់សត្វមានប្រយោជន៍ សុខភាព និងបរិស្ថាន។

### ២.៥. ដង្កូវរយ

- ត្រូវភ្ជួររាស់ដីឱ្យបានស្អាតល្អ ដើម្បីកម្ចាត់ដឹកឿ និងដង្កូវមុននឹងដាំដុះ
- សំអាតស្មៅជុំវិញស្រែ ដែលជាជម្រកសម្រាប់មេអំបៅដង្កូវរយ
- បញ្ចូលទឹកក្នុងស្រែ រួចតកន្ទ្រងបក់ដើម្បីប្រមូលដង្កូវមកកម្ទេច

- ថែរក្សាសត្វមានប្រយោជន៍ ដោយកាត់បន្ថយការប្រើថ្នាំកសិកម្មគីមី
- ជីកចង្អូរជុំវិញ និងរោយផេះ ដើម្បីទប់ស្កាត់ដង្កូវហ្វូងវារឆ្លងពីស្រែផ្សេង ក្នុងករណីមានការផ្ទុះរាលដាល
- ក្នុងករណីអនុវត្តវិធានការទាំងអស់ខាងលើមិនអាចទប់ស្កាត់បាន គួរប្រើប្រាស់ថ្នាំកសិកម្មគីមី ដោយពិភាក្សាជាមួយអ្នកជំនាញ និងជ្រើសរើសថ្នាំដែលមិនប៉ះពាល់ខ្លាំងដល់សត្វមានប្រយោជន៍ សុខភាព និងបរិស្ថាន ។

## ២.៦. ដង្កូវមូរស្លឹក

- ស្ទូងស្រូវឱ្យឆ្ងាយពីម្លប់ និងជៀសវាងស្ទូងស្រូវញឹកពេក
- ធ្វើអនាម័យស្រែដោយសំអាតជម្រករបស់មេអំបៅ
- ប្រើបរិមាណជីឱ្យបានសមស្រប និងមានតុល្យភាព ( ជៀសវាងប្រើជីអាសូតច្រើនពេក)
- ប្រើឈើដែលមានបន្លាអូស ឬប្រើរំពាត់វាសលើស្លឹកស្រូវនៅពេលថ្ងៃក្ដៅខ្លាំង
- ថែរក្សាសត្វមានប្រយោជន៍ ដោយកាត់បន្ថយការប្រើថ្នាំកសិកម្មគីមី
- ក្នុងករណីអនុវត្តវិធានការទាំងអស់ខាងលើមិនអាចទប់ស្កាត់បាន គួរប្រើប្រាស់ថ្នាំកសិកម្មគីមី ដោយពិភាក្សាជាមួយអ្នកជំនាញ និងជ្រើសរើសថ្នាំដែលមិនប៉ះពាល់ខ្លាំងដល់សត្វមានប្រយោជន៍ សុខភាព និងបរិស្ថាន ។

## ២.៧. សង្កើចខ្មៅ

- ធ្វើអនាម័យស្រែដោយសំអាតជម្រករបស់វា
- ប្រើបរិមាណជីឱ្យបានសមស្រប និងមានតុល្យភាព
- ពន្លិចទឹកស្រែ រួចប្រើស្បៃមុងអូសប្រមូលសង្កើតខ្មៅយកមកកម្ទេចចោល
- បញ្ចេញទឹកពីក្នុងស្រែ ព្រោះសង្កើចខ្មៅមិនចូលចិត្តអាកាសធាតុក្ដៅ
- ប្រមូលសង្កើចខ្មៅរួចបុក និងលាយទឹកបាញ់លើស្រែទាំងមូលដើម្បីបណ្ដេញ
- ក្នុងករណីអនុវត្តវិធានការទាំងអស់ខាងលើមិនអាចទប់ស្កាត់បាន គួរប្រើប្រាស់ថ្នាំកសិកម្មគីមី ដោយពិភាក្សាជាមួយអ្នកជំនាញ និងជ្រើសរើសថ្នាំដែលមិនប៉ះពាល់ខ្លាំងដល់សត្វមានប្រយោជន៍ សុខភាព និងបរិស្ថាន ។

## ២.៨. សត្វស្រឹងជញ្ជក់ទឹកដោះ

- ធ្វើអនាម័យស្រែ ដោយសំអាតជម្រករបស់វា
- ប្រើប្រាស់សាប៊ូក្រអូប លាយទឹកបាញ់លើស្រែដើម្បីបណ្ដេញ
- ប្រើប្រាស់ប្រហុក នៅខាងក្រៅស្រែ ដើម្បីទាក់ទាញសត្វស្រឹង
- ប្រើស្បៃមុងអូសប្រមូលស្រឹងជញ្ជក់ទឹកដោះ រួចបុកលាយទឹក ហើយបាញ់ទៅក្នុងស្រែវិញដើម្បីបណ្ដេញ
- ថែរក្សាសត្វមានប្រយោជន៍ ដោយកាត់បន្ថយការប្រើថ្នាំកសិកម្មគីមី
- ក្នុងករណីអនុវត្តវិធានការទាំងអស់ខាងលើមិនអាចទប់ស្កាត់បាន គួរប្រើប្រាស់ថ្នាំកសិកម្មគីមី ដោយពិភាក្សាជាមួយអ្នកជំនាញ និងជ្រើសរើសថ្នាំដែលមិនប៉ះពាល់ខ្លាំងដល់សត្វមានប្រយោជន៍ សុខភាព និងបរិស្ថាន ។

| ២.៩. ខ្យងពណ៌មាស |
| --- |
| - ត្រូវរៀបចំឱ្យមានចង្អូរនៅក្នុងស្រែ និងដោតបង្គោលនៅតាមចង្អូរឱ្យខ្យងឡើងពងដាក់ រួចប្រមូលពងកម្ទេចចោល<br>- បង្ហូរទឹកចេញពីស្រែ រួចប្រមូលខ្យងនៅតាមចង្អូរទៅកម្ទេចចោល<br>- ប្រលែងសត្វទាឱ្យស៊ីខ្យង ដោយអនុវត្តប្រព័ន្ធកសិកម្មចម្រុះស្រូវ-ទា<br>- រៀបចំទិវាកម្ចាត់ខ្យងជាសហគមន៍ រួចប្រមូលទិញ បំផ្លាញ និងធ្វើជាចំណីសត្វ<br>- ក្នុងករណីអនុវត្តវិធានការទាំងអស់ខាងលើមិនអាចទប់ស្កាត់បាន គួរប្រើប្រាស់ថ្នាំកសិកម្មគីមី ដោយពិភាក្សាជាមួយអ្នកជំនាញ និងជ្រើសរើសថ្នាំដែលមិនប៉ះពាល់ខ្លាំងដល់សត្វមានប្រយោជន៍ សុខភាព និងបរិស្ថាន ។ |
| **២.១០. សត្វកណ្តុរ** |
| - ត្រូវបំផ្លាញជម្រក និងកម្ចាត់កណ្តុរជាសហគមន៍ តាមរយៈការរៀបចំទិវាកម្ចាត់កណ្តុរ ឬទិញកណ្តុរ<br>- ដាក់បំពង់ឫស្សី ឬទុយោក្បែរភ្លឺស្រែដើម្បីប្រមូលកណ្តុរ (ផ្ទះសំណាក់កណ្តុរ)<br>- ប្រើអង្គប់ចាប់កណ្តុរ<br>- ប្រើកៅស៊ូប្លាស្ទិច ធ្វើជារបាំងជុំវិញស្រែ<br>- ដាក់នុយបំពុល<br>- ប្រើខ្សែលួស និងអាគុយសម្រាប់ឆក់នៅពេលយប់ (តែត្រូវប្រុងប្រយ័ត្ន ចំពោះសុវត្ថិភាពនៅពេលប្រើប្រាស់)<br>- ថែរក្សាសត្វប្រេដាទ័រមួយចំនួន ដូចជា ពស់ថ្លាន់ ទីទុយ ខ្លែងស្រាក ។ល។ |

# ផ្នែកទី III

# ការកម្ចាត់សមាសភាពចង្រៃ

# ដោយប្រើប្រាស់ថ្នាំកសិកម្ម

## គ. ការប្រុងប្រយ័ត្នចំពោះការប្រើប្រាស់ថ្នាំកសិកម្ម

គ្រប់ថ្នាំកសិកម្មទាំងអស់គឺសុទ្ធតែពុល ប្រសិនបើយើងប្រើប្រាស់វាមិនបានសមស្រប ដូច្នេះមុននឹងប្រើប្រាស់វា សូមអនុវត្តទៅតាមការណែនាំស្តីពីការប្រុងប្រយ័ត្ន និងសុវត្ថិភាពក្នុងការប្រើប្រាស់ដែលមានប្រាប់បង្ហាញនៅលើសំបកវេចខ្ចប់ថ្នាំទាំងនោះ ។

សូមរក្សាទុកដាក់ថ្នាំកសិកម្ម នៅក្នុងសំបកវេចខ្ចប់ដើមរបស់វា ដោយធ្វើការទុកដាក់នៅក្នុងប្រអប់ចាក់សោរមួយត្រឹមត្រូវ ។

ត្រូវរក្សាទុកដាក់ថ្នាំកសិកម្មដាច់ដោយឡែកពីម្ហូបអាហារ ដាក់ឱ្យផុតពីដៃក្មេង សត្វចិញ្ចឹម និងសត្វពាហនៈ ។

បាញ់ថ្នាំឱ្យនៅតែក្នុងបរិវេណតែត្រូវបានកំនត់ ជៀសវាងធ្វើឱ្យដំណក់ទឹកថ្នាំដែលបាញ់ទៅប៉ះលើកន្លែងផ្សេងទៀត ជាពិសេសលើដំណាំដែលជិតប្រមូលផល ។

សូមកុំយកសំបកដបថ្នាំដែលប្រើអស់យកទៅប្រើប្រាស់ឡើងវិញឱ្យសោះ ហើយក៏មិនត្រូវបោះវាចោលនៅកន្លែងដែលអាចបង្កឱ្យមានផលប៉ះពាល់ដល់ប្រភពទឹកផងដែរ ។

សូមធ្វើការទំនាក់ទំនងមកភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ដែលប្រចាំការនៅក្នុងតំបន់លោកអ្នក ដើម្បីទទួលបាននូវព័ត៌មានលំអិតអំពីការប្រើប្រាស់ថ្នាំកសិកម្មឱ្យបានសមស្របទៅតាមបច្ចេកទេស ។

**សូមចងចាំថា ការប្រើប្រាស់ថ្នាំកសិកម្មមិនបានត្រឹមត្រូវ នឹងមិនត្រឹមតែ**
**បង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ប៉ុណ្ណោះទេ ថែមទាំងបង្កគ្រោះមហន្តរាយ**
**ដល់អ្នកដទៃទៀត និងធ្វើអោយហិនហោចដល់ជីវចម្រុះនានាដែលមាននៅក្នុងបរិស្ថាន ។**
**មានន័យថា ការប្រើប្រាស់ថ្នាំកសិកម្មមិនបានត្រឹមត្រូវ ជាការបំផ្លាញខ្លួនឯង និងអ្នកដទៃ ។**

## ខ. របៀបមើលព័ត៌មាននៅលើសំបកដបថ្នាំកសិកម្ម

នៅពេលដែលយើងសម្រេចចិត្តជ្រើសប្រើថ្នាំកសិកម្មជាវិធានការចុងក្រោយបង្អស់ យើងត្រូវធ្វើការជ្រើសរើសថ្នាំកសិកម្មឱ្យបានត្រឹមត្រូវសម្រាប់ប្រើលើសមាសភាពចង្រៃដែលយើងចង់កម្ចាត់ ។ យើងមិនត្រូវគិតថាការជ្រើសរើសប្រើថ្នាំកសិកម្ម ដោយសារតែតម្លៃរបស់វាថោកនោះឡើយ។ ការគិតបែបនេះគឺជាការខ្ជះខ្ជាយពេលវេលា និងថវិកា ប្រសិនបើការប្រើប្រាស់ទៅមិនមានប្រសិទ្ធភាពក្នុងការកម្ចាត់សមាសភាពចង្រៃបាន។

ព័ត៌មាននៅលើសំបកដបថ្នាំកសិកម្ម មានសារសំខាន់ណាស់សម្រាប់អ្នកប្រើប្រាស់ ក្នុងការស្វែងយល់ឱ្យបានត្រឹមត្រូវ និងអាចឱ្យដឹងថា តើថ្នាំកសិកម្មប្រភេទណាដែលគួរទិញ និងជ្រើសរើសយកមកប្រើប្រាស់ដើម្បីកម្ចាត់នូវសមាសភាពចង្រៃនានាដែលកំពុងជួបប្រទះប្រកបដោយប្រសិទ្ធភាព។

ហេតុដូច្នេះហើយ នៅក្នុងផ្នែកនេះនឹងមានពន្យល់បង្ហាញអំពីព័ត៌មានសំខាន់ៗដែលមាននៅលើសំបកដបថ្នាំកសិកម្មដែលអ្នកប្រើប្រាស់ថ្នាំកសិកម្មត្រូវតែដឹង ដើម្បីអាចជ្រើសរើស និងប្រើប្រាស់ថ្នាំកសិកម្មឱ្យបានត្រឹមត្រូវក្នុងការកម្ចាត់សមាសភាពចង្រៃ ។

ខាងក្រោមនេះ គឺជាគំរូព័ត៌មានអំពីផ្នែកនីមួយៗ ដែលអ្នកប្រើប្រាស់ត្រូវស្វែងយល់។

១. ការប្រុងប្រយ័ត្ន

ប្រាប់អំពីប្រភេទគ្រោះថ្នាក់ ដែលអាចប្រឈមនៅពេលធ្វើការទុកដាក់ និងប្រាប់ឱ្យដឹងពីប្រការដែលត្រូវជៀសវាង ប្រាប់ពីរបៀបក្នុងការជួយសង្គ្រោះបឋម និងប្រភេទនៃគ្រោះថ្នាក់ដែលត្រូវការព្យាបាលដោយគ្រូពេទ្យ ។ល។

២. របៀបប្រើប្រាស់

ព័ត៌មានត្រង់ចំណុចនេះ ប្រាប់អំពីរបៀបនៃការប្រើប្រាស់ថ្នាំឱ្យបានត្រឹមត្រូវ ដើម្បីទទួលបាននូវប្រសិទ្ធិភាព។ វាជាការចាំបាច់ណាស់ ក្នុងការធ្វើតាមអ្វីដែលមាននៅក្នុងសេចក្តីណែនាំ ដូចជាកំរិតប្រើថ្នាំ និងប្រភេទដំណាំ ដែលថ្នាំអាចប្រើលើបាន ។ កំរិតប្រើ គឺជាបរិមាណថ្នាំកសិកម្ម ដែលគេប្រើក្នុងមួយហិកតា ហើយដែលត្រូវបានធ្វើការវាយតម្លៃតាមរយៈការពិសោធន៍ និងដោយក្រុមហ៊ុនផលិតថ្នាំ។ បរិមាណថ្នាំដែលត្រូវប្រើ គឺត្រូវតែអនុវត្តឱ្យបានទៅតាមការណែនាំ ដើម្បីជៀសវាងការប្រើប្រាស់បែបខ្ជះខ្ជាយ ។

ឧទាហរណ៍: អំពីការអានព័ត៌មាននៅលើសំបកដបថ្នាំកសិកម្ម



រូបសញ្ញាដែលពាក់ពន្ធ័នឹងការប្រើប្រាស់ថ្នាំកសិកម្ម

ពាក់ព័ន្ធនឹងពាក្យថា "ប្រុងប្រយ័ត្ន" និង "ការប្រើប្រាស់" មាននិមិត្តសញ្ញាដែលជាការបង្គាប់បញ្ជា ។ និមិត្តសញ្ញាដែលតែងតែជួបប្រទះញឹកញាប់រួមមាន :

និមិត្តសញ្ញាគ្រោះថ្នាក់

| | | | |
|---|---|---|---|
|  |  |  |  |
| អាចកាត់បំផ្លាញលោហៈធាតុ និងធ្វើឱ្យស្បែកខូចទ្រង់ទ្រាយ | បង្កការរលាក ឬគ្រោះថ្នាក់ | ពុល | គ្រោះថ្នាក់ដល់បរិស្ថាន |

| | | |
|---|---|---|
|  |  |  |
| គ្រោះថ្នាក់/ពុលដល់សត្វ | គ្រោះថ្នាក់/ពុលដល់ត្រី | ទុកដាក់ក្នុងទូចាក់សោរ និងផុតពីដៃក្មេង |

និមិត្តសញ្ញាបង្គាប់បញ្ជា

| | | | |
|---|---|---|---|
|  |  |  |  |
| លាងសំអាតខ្លួន ក្រោយពេលប្រើថ្នាំ | ពាក់អាវការពារ | ពាក់ស្បែកជើងកវែង | ពាក់របាំងការពារមុខ |

| | | | |
|---|---|---|---|
|  |  |  |  |
| ពាក់ស្រោមដៃ | ពាក់ម៉ាសការពារច្រមុះ និងមាត់ | ស្លៀកសំលៀកបំពាក់ឱ្យជិតខ្លួនប្រាណ | ពាក់ម៉ាស់ពិសេស |

៣. ការចុះបញ្ជិកា

វាមានសារៈសំខាន់ណាស់ចំពោះអ្នកប្រើប្រាស់ដើម្បីពិនិត្យ ថាតើថ្នាំកសិកម្មមានលេខបញ្ជិកា ឬក៏អត់ ប្រសិនបើគ្មានលេខបញ្ជិកាដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនោះទេ វាគឺជាថ្នាំដែលខុសច្បាប់។ ថ្នាំកសិកម្មដែលមានលេខបញ្ជិកា គឺជាផលិតផលដែលមានការទទួលស្គាល់គុណភាព ដោយបានឆ្លងកាត់ការត្រួតពិនិត្យយ៉ាងត្រឹមត្រូវ ។

៤. ប្រភេទ ឬទម្រង់របស់ថ្នាំកសិកម្ម

នៅក្នុងថ្នាំកសិកម្ម មានតែសារធាតុមួយចំនួនប៉ុណ្ណោះ ដែលអាចប្រយុទ្ធប្រឆាំងនឹងសមាសភាពចង្រៃ ហើយសារធាតុនោះ គឺត្រូវបានគេហៅថា "សារធាតុសកម្ម" ។

សារធាតុសកម្មនេះ គឺមិនត្រូវបានគេយកមកប្រើតែឯកឯងនោះឡើយ។ ដូច្នេះហើយវាត្រូវបានគេលាយបញ្ចូលជាមួយសារធាតុផ្សេងទៀតជាច្រើន ដើម្បីបង្កើតទៅជាថ្នាំកសិកម្មក្នុងទម្រង់មួយ ដែលធ្វើឱ្យសារធាតុសកម្មនោះកាន់តែមានប្រសិទ្ធិភាព មានលក្ខណៈងាយស្រួលក្នុងការយកមកប្រើ និងបង្កការងាយស្រួលដល់ការរក្សាទុក ។ ទម្រង់ថ្នាំកសិកម្មរួមមាន : Emulsifiable Concentrate (EC) ទម្រង់ជាម្សៅទឹក (WP) ទម្រង់ជាគ្រាប់ (G) ។ល។ សូមបញ្ជាក់ថា រាល់ទម្រង់នីមួយៗរបស់ថ្នាំកសិកម្ម សុទ្ធតែមានគុណសម្បត្តិ និងគុណវិបត្តិពិសេសរបស់វា ។

<u>គ្រោះថ្នាក់/ភាពពុល</u>

ដើម្បីការពារសុខភាពរបស់យើង និងកាត់បន្ថយការប៉ះពាល់ដល់បរិស្ថាន យើងត្រូវដឹងពីគ្រោះថ្នាក់ និងភាពពុលរបស់ថ្នាំកសិកម្ម ។ យើងត្រូវចងចាំថា ថ្នាំដែលមានកំរិតជាតិពុលខ្លាំងបំផុតចំពោះមនុស្ស មិនមែនមានន័យថាវាពុលខ្លាំងចំពោះសត្វល្អិតឡើយ ។ ចំណាត់ថ្នាក់នៃកំរិតពុលរបស់ថ្នាំកសិកម្មរបស់អង្គការសុខភាពពិភពលោក (WHO) ត្រូវបានគេយកមកប្រើយ៉ាងទូលំទូលាយ។ ក្រៅពីនេះនៅមានចំណាត់ថ្នាក់ជាច្រើនដែលធ្វើឡើងដោយស្ថាប័នផ្សេងទៀតដូចជា ទីភ្នាក់ងារការពារបរិស្ថាន (EPA) របស់សហរដ្ឋអាមេរិកជាដើម។

ដោយផ្អែកទៅលើការចាត់ថ្នាក់ថ្នាំកសិកម្ម របស់អង្គការសុខភាពពិភពលោក (WHO) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ធ្វើការបែងចែកថ្នាំកសិកម្មដូចជា: ថ្នាំកសិកម្មដែលអនុញ្ញាតិឱ្យប្រើប្រាស់ ថ្នាំកសិកម្មដែលអនុញ្ញាតិឱ្យប្រើប្រាស់តែស្ថិតនៅក្នុងលក្ខខណ្ឌ និងថ្នាំកសិកម្មដែលហាមឃាត់មិនឱ្យប្រើប្រាស់។

ចំពោះព័ត៌មានលំអិត ស្តីពីការបែងចែកប្រភេទថ្នាំកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការទំនាក់ទំនងមកកាន់ការិយាល័យកសិកម្មដែលនៅជិតលោកអ្នកបំផុត។

តារាងខាងក្រោមនេះជាការចាត់ចំណាត់ថ្នាក់ លើភាពពុលរបស់ថ្នាំកសិកម្ម និងពណ៌របស់វណ្ឌនៅលើសំបកដបដែលមាននៅលើសំបកថ្នាំកសិកម្មរបស់ប្រទេសកម្ពុជា ថៃ និងវៀតណាម និងស្លាកសញ្ញាព័ត៌មាន ពិតប្រាកដដែលបង្ហាញពី ពណ៌របស់វណ្ឌនៅលើសំបកវេចខ្ចប់:

| **កំរិតគ្រោះថ្នាក់ /ភាពពុល** | **ការចាត់ថ្នាក់ថ្នាំកសិកម្មរបស់អង្គការសុខភាពពិភពលោក** (WHO) | **ចំណាត់ថ្នាក់នៃគ្រោះថ្នាក់ និងពណ៌វណ្ឌដែលមាននៅលើស្លាកសញ្ញាព័ត៌មាន** | | |
|---|---|---|---|---|
| | | **ប្រទេសកម្ពុជា** | **ប្រទេសថៃ** | **ប្រទេសវៀតណាម** |
| ពុលក្រៃលែង | ចំណាត់ថ្នាក់ $I_a$ | ពុលខ្លាំង | ពុលក្រៃលែង | ក្រិត I: ពុលក្រៃលែង |
| ពុលខ្លាំង | ចំណាត់ថ្នាក់ $I_b$ | | ពុលខ្លាំង | |
| ពុលមធ្យម | ចំណាត់ថ្នាក់ II | ពុលមធ្យម | ពុលមធ្យម | ក្រិត II : ពុលខ្លាំង |
| ពុលខ្សោយ | ចំណាត់ថ្នាក់ III | ពុលខ្សោយ | ពុលខ្សោយ | គ្រោះថ្នាក់ |
| ពុលតិចតួច | មិនសូវពុលធ្ងន់ធ្ងរនៅក្នុងការប្រើប្រាស់ធម្មតា | | មិនសូវពុល | |

(ឯកសារយោង: សៀវភៅណែនាំសម្រាប់អាជីវករលក់ថ្នាំកសិកម្ម របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)

## ៥ ប្រភេទថ្នាំកសិកម្ម

មុននឹងជ្រើសរើសថ្នាំកសិកម្មយកមកប្រើ យើងចាំបាច់បំផុតត្រូវដឹងពី ប្រភេទថ្នាំដែលត្រូវប្រើលើសមាសភាពចង្រៃដែលយើងចង់កម្ចាត់។

ថ្នាំកសិកម្មមាន ៧ ប្រភេទសំខាន់ៗ:

១. ថ្នាំកម្ចាត់សត្វល្អិត
២. ថ្នាំកម្ចាត់ជំងឺ

៣. ថ្នាំកម្ចាត់ស្មៅ
៤. ថ្នាំកម្ចាត់អាការីត ឬចៃ
៥. ថ្នាំកម្ចាត់កណ្ដុរ
៦. ថ្នាំកម្ចាត់ខ្យង
៧. ថ្នាំកម្ចាត់ណេម៉ាតូត

**៦. ឈ្មោះក្រុមហ៊ុនផលិត និងចែកចាយថ្នាំកសិកម្ម**

អ្នកប្រើប្រាស់ចាំបាច់ត្រូវពិនិត្យមើលថា តើក្រុមហ៊ុនដែលផលិត ឬក្រុមហ៊ុនដែលចែកចាយថ្នាំកសិកម្មទាំងនោះ មានអាជ្ញាបណ្ណ័ត្រឹមត្រូវចេញដោយក្រសួងកសិកម្មដែរឬទេ ព្រោះថាការលក់ ឬចែកចាយផលិតផលដោយមិនមានអាជ្ញាបណ្ណ័ គឺជាអំពើផ្ទុយនឹងច្បាប់ ។

សូមធ្វើការទំនាក់ទំនងជាមួយមន្ត្រីកសិកម្មដែលនៅជិតលោកអ្នកបំផុតដើម្បីដឹងថាតើក្រុមហ៊ុនចែកចាយថ្នាំកសិកម្មណាដែលស្របច្បាប់ ។



**ឧទាហរណ៍ ១ : វណ្ណពណ៌ក្រហមនៅលើសំបកដបថ្នាំកសិកម្ម**

Source: [http://thailand.ipm-info.org/your_poison/07_what_types_of_pesticides.htm](http://thailand.ipm-info.org/your_poison/07_what_types_of_pesticides.htm))




**ឧទាហរណ៍ ២ : វណ្ណពណ៌លឿងនៅលើសំបកដបថ្នាំកសិកម្ម**

គ. ឈ្មោះធាតុសកម្មរបស់ថ្នាំកសិកម្មសម្រាប់ប្រើកម្ចាត់សត្វល្អិតចង្រៃ និងជំងឺលើដំណាំស្រូវ

| ល.រ | សត្វល្អិត/ជំងឺ | ឈ្មោះធាតុសកម្មរបស់ថ្នាំកសិកម្ម |
|---|---|---|
| ១ | ដង្កូវហ្វូង | (1) ក្លរពីរីហ្វូស Chlorpyrifos<br>(2) សាយភើមេទ្រីន Cypermethrin<br>(3) ដែតាមេទ្រីន Deltamethrin<br>(4) ឌីយ៉ាហ្ស៊ីណន់ Diazinon<br>(5) អេម៉ាមិកទីន បង់ហ្សូអែត Emamectin benzoate<br>(6) ហ្វិនវ៉ាឡឺរ៉េត Fenvalerate<br>(7) គីណាល់ហ្វូស Quinalfos<br>Others |
| ២ | សង្កើចខ្មៅ | (1) កាបូស៊ុលហ្វាន Carbosulfan<br>Others |
| ៣ | មមាចត្នោត | (1) ប៊ុយប្រូហ្វេហ្ស៊ីន Buprofezin<br>(2) ក្លរពីរីហ្វូស Chlorpyrifos<br>(3) ឌីណូតេហ្វុយរ៉ាន Dinotefuran<br>(4) អេតូហ្វិនប្រុក Etofenprox<br>(5) ហ្វេណូប៊ុយកាប Fenobucarb<br>(6) ហ្វីប្រូនីល Fipronil<br>(7) អ៊ីមីដាក្លូព្រីត Imidacloprid<br>Others |
| ៤ | ខ្យងមាស | (1) មេតាល់ដេអ៊ីត Metaldehyde<br>(2) នីក្លូសាមីត Niclosamide<br>Others |
| ៥ | មមាចខៀវ | (1) ប៊ុយប្រូហ្វេហ្ស៊ីន Buprofezin<br>(2) ដែតាមេទ្រីន Deltamethrin<br>(3) ឌីណូតេហ្វុយរ៉ាន Dinotefuran<br>(4) អេតូហ្វិនប្រុក Etofenprox<br>(5) ហ្វេណូប៊ុយកាប Fenobucarb<br>(6) ហ្វីប្រូនីល Fipronil<br>(7) អ៊ីមីដាក្លូព្រីត Imidacloprid<br>(8) កាបូហ្វុយរ៉ាន Carbofuran<br>(9) អ៊ីសូប្រូកាប Isoprocarb<br>Others |

| | | |
|---|---|---|
| ៦ | ដង្កូវមូរស្លឹក | (1) អាបាមិកទីន Abamectin<br>(2) កាតាប Cartap<br>(3) ក្លរ៉ានត្រានីលីប្រុល Chlorantraniliprole<br>(4) ក្លរពីរីហ្វុស Chlorpyrifos<br>(5) សាយភឺមេទ្រីន Cypermethrin<br>(6) ដែតាមេទ្រីន Deltamethrin<br>(7) ឌីយ៉ាហ្ស៊ីណន់ Diazinon<br>(8) អេម៉ាមិកទីន បង់ហ្សូអែត Emamectin benzoate<br>(9) ហ្វេនីត្រូធុង Fenitrothion<br>(10) ហ្វីប្រូនីល Fipronil<br>(11) គីណាល់ហ្វូស Quinalphos<br>Others |
| ៧ | ស្រីង | (1) ដែតាមេទ្រីន Deltamethrin<br>(2) អេតូហ្វិនប្រុក Etofenprox<br>(3) ហ្វេនីត្រូធុង Fenitrothion<br>Others |
| ៨ | ដង្កូវបំពង់កាត់ស្លឹក | (1) ដែតាមេទ្រីន Deltamethrin<br>(2) ឌីយ៉ាហ្ស៊ីណន់ Diazinon<br>Others |
| ៩ | ទ្រីប | (1) សាយភឺមេទ្រីន Cypermethrin<br>(2) ដែតាមេទ្រីន Deltamethrin<br>(3) ឌីមេតូអែត Dimethoate<br>(4) ឌីណូតេហ្វុយរ៉ាន Dinotefuran<br>(5) អេម៉ាមិកទីន បង់ហ្សូអែត Emamectin benzoate<br>Others |
| ១០ | ដង្កូវស៊ីរូងដើម | (1) អាបាមិកទីន Abamectin<br>(2) កាតាប Cartap<br>(3) ក្លរ៉ានត្រានីលីប្រុល Chlorantraniliprole<br>(4) ដែតាមេទ្រីន Deltamethrin<br>(5) ឌីយ៉ាហ្ស៊ីណន់ Diazinon<br>(6) ឌីណូតេហ្វុយរ៉ាន Dinotefuran<br>(7) អេម៉ាមិកទីន បង់ហ្សូអែត Emamectin benzoate<br>(8) ហ្វីប្រូនីល Fipronil<br>Others |
| ១១ | ជំងឺច្រែះស្លឹក /ជំងឺប្លាស | (1) បេណូមីល Benomyl<br>(2) កាបិនដាហ្ស៊ីម Carbendazim<br>(3) អ៊ីសូប្រូត្យូឡាន Isoprothiolane |

| | | |
|---|---|---|
| | | (4) ទ្រីស៊ីក្លាហ្សូល Tricyclazole<br>Others |
| ១២ | ជំងឺរលាកស្លឹកបង្កដោយបាក់តេរី | មិនមាន |
| ១៣ | ជំងឺឆ្នូតស្លឹកបណ្ដាលមកពីបាក់តេរី | មិនមាន |
| ១៤ | ជំងឺទង់គ្រោ | កម្ចាត់សត្វល្អិតដែលចម្លងជំងឺ ជាពិសេសមមាចខៀវ ។ |
| ១៥ | ជំងឺតឿស្មៅ | កម្ចាត់សត្វល្អិតដែលចម្លងជំងឺ ជាពិសេសមមាចត្នោត ។ |
| ១៦ | ជំងឺតឿរួញស្លឹក | កម្ចាត់សត្វល្អិតដែលចម្លងជំងឺ ជាពិសេសមមាចត្នោត ។ |
| ១៧ | ជំងឺរលួយស្រទបស្លឹក | (1) បេណូមីល Benomyl<br>(2) កាបិនដាហ្សីម Carbendazim<br>(3) ខូបភឺអុកស៊ីក្លរីដ Copper oxychloride<br>(4) អ៊ិចហ្សាកូណាហ្សូល Hexaconazole<br>(5) ម៉ង់កូហ្សែប Mancozeb<br>(6) ប្រូក្លរ៉ាស់ Prochloraz<br>(7) ប្រូពីកូណាហ្សូល Propiconazole<br>(8) ប្រូពីណែប Propineb<br>(9) ត្យូហ្វាណាត មេទីល Thiophanate methyl<br>Others |
| ១៨ | ជំងឺរលាកស្រទបស្លឹក | (1) បេណូមីល Benomyl<br>(2) កាបិនដាហ្សីម Carbendazim<br>(3) អ៊ីប្រូដ្យូន Iprodione<br>(4) ផែនស៊ីកុយរ៉ុង Pencycuron<br>(5) ប្រូពីកូណាហ្សូល Propiconazole<br>(6) ទ្រីស៊ីក្លាហ្សូល + ប្រូពីកូណាហ្សូល<br>Triciclazole+Propiconazole<br>(7) វ៉ាលីដាមីស៊ីន Validamycin<br>Others |

## ឃ. ឈ្មោះធាតុសកម្មរបស់ថ្នាំកសិកម្មសម្រាប់ប្រើកម្ចាត់សត្វល្អិតចង្រៃ និងជំងឺលើដំណាំស្ពៃ

| ល.រ | សត្វល្អិត/ជំងឺ | ឈ្មោះធាតុសកម្មរបស់ថ្នាំកសិកម្ម |
|---|---|---|
| ១ | ដង្កូវហ្វូង | (1) អាបាមិកទីន Abamectin<br>(2) អាហ្សាឌីរ៉ាកទីន Azadirachtin<br>(3) បាក់ស៊ីឡុស ធួរិនហ្ស៊ិនស៊ីស Bacillus thuringiensis<br>(4) កាបារីល Carbaryl<br>(5) ក្លរ៉ានត្រានីលីប្រូល Chlorantraniliprole<br>(6) ក្លរពីរីហ្វូស Chlorpyrifos<br>(7) សាយភឺមេទ្រីន Cypermethrin<br>(8) អេម៉ាមិកទីន បង់ហ្សូអែត Emamectin benzoate<br>(9) អេសហ្វិនវ៉ាឡឺរ៉េត Esfenvalerate<br>(10) អេតូហ្វិនប្រុក Etofenprox<br>(11) ម៉ាឡាធុង Malathion<br>(12) ភឺមេទ្រីន Permethrin<br>(13) ស្ពីណូសាដ Spinosad<br>Others |
| ២ | ដង្កូវកាត់ដើម | (1) អាសេហ្វាត Acephate<br>(2) ក្លរពីរីហ្វូស Chlorpyriphos<br>(3) សាយហ្វ្លូទ្រីន Cyfluthrin<br>(4) សាយភឺមេទ្រីន Cypermethrin<br>(5) ឌីយ៉ាហ្ស៊ីណន់ Diazinon<br>(6) អេសហ្វិនវ៉ាឡឺរ៉េត Esfenvalerate<br>(7) ហ្វិនប្រូប៉ាទ្រីន Fenpropathrin<br>(8) ឡាំដាសាយហាឡូទ្រីន Lambda cyhalothrin<br>(9) ភឺមេទ្រីន Permethrin<br>Others |
| ៣ | ដង្កូវស៊ីរូងបណ្តូលស្ពៃ | (1) អាបាមិកទីន Abamectin<br>(2) បាក់ស៊ីឡុស ធួរិនហ្ស៊ិនស៊ីស Bacillus thuringiensis<br>(3) សាយភឺមេទ្រីន Cypermethrin<br>(4) ដែតាមេទ្រីន Deltamethrin<br>(5) អេម៉ាមិកទីន បង់ហ្សូអែត Emamectin benzoate<br>(6) ភឺមេទ្រីន Permethrin<br>Others |

| | | |
|---|---|---|
| ៤ | ដង្កូវបាក់ខ្នង | (1) អាសេហ្វាត Acephate<br>(2) អាហ្សាឌីរ៉ាកទីន Azadirachtin<br>(3) បាក់ស៊ីឡុស តួរិនហ៊្សិនស៊ីស Bacillus thuringiensis<br>(4) កាបារីល Carbaryl<br>(5) ក្លរ៉ានត្រានីលីប្រូល Chlorantraniliprole<br>(6) ក្លរពីរីហ្វូស Chlorpyrifos<br>(7) សាយហ្លូទ្រីន Cyfluthrin<br>(8) សាយភឺមេទ្រីន Cypermethrin<br>(9) អេម៉ាមិកទីន បង់ហ្សូអែត Emamectin benzoate<br>(10) អេសហ្វិនវ៉ាឡឺរ៉េត Esfenvalerate<br>(11) ហ្វិនប្រូប៉ាទ្រីន Fenpropathrin<br>(12) ឡាំដាសាយហាឡូទ្រីន Lambda cyhalothrin<br>(13) ម៉ាឡាចុង Malathion<br>(14) ភឺមេទ្រីន Permethrin<br>(15) ស្ពីណូសាដ Spinosad<br>Others |
| ៥ | ដង្កូវស៊ីត្រួយ | (1) អាបាមិកទីន Abamectin<br>(2) អាសេហ្វាត Acephate<br>(3) បាក់ស៊ីឡុស តួរិនហ៊្សិនស៊ីស Bacillus thuringiensis<br>(4) ក្លរ៉ានត្រានីលីប្រូល Chlorantraniliprole<br>(5) ក្លរពីរីហ្វូស Chlorpyrifos<br>(6) អេតូហ្វិនប្រុក Etofenprox<br>(7) ភឺមេទ្រីន Permethrin<br>(8) ប្រូហ្វេណូហ្វូស Profenopos<br>(9) ស្ពីណូសាដ Spinosad<br>(10) តេប៊ុយហ្វេណូហ្ស៊ីដ Tebufenozide<br>Others |
| ៦ | ដង្កូវយោលទោង | (1) អាបាមិកទីន Abamectin<br>(2) អាសេហ្វាត Acephate<br>(3) អាហ្សាឌីរ៉ាកទីន Azadirachtin<br>(4) បាក់ស៊ីឡុស តួរិនហ៊្សិនស៊ីស Bacillus thuringiensis<br>(5) កាបារីល Carbaryl<br>(6) កាតាប Cartap<br>(7) ក្លរពីរីហ្វូស Chlorpyrifos |

| | | |
|---|---|---|
| | | (8) ក្លរ៉ានត្រានីលីប្រុល Chlorantraniliprole<br>(10) សាយហ្លូទ្រីន Cyfluthrin<br>(11) សាយភឺមេទ្រីន Cypermethrin<br>(12) ដែតាមេទ្រីន Deltamethrin<br>(13) ឌីយ៉ាហ្ស៊ីណន់ Diazinon<br>(14) ឌីណូតេហ្វុយរ៉ាន Dinotefuran<br>(15) អេម៉ាមិកទីន បង់ហ្សូអែត Emamectin benzoate<br>(16) អេសហ្វិនវ៉ាឡឺរ៉េត Esfenvalerate<br>(17) អេតូហ្វិនប្រុក Etofenprox<br>(18) ហ្វិនប្រូប៉ាទ្រីន Fenpropathrin<br>(19) ហ្វីប្រូនីល Fipronil<br>(20) អ៊ិនដូហ្សាកាប Indoxacarb<br>(21) ឡាំដាសាយហាឡូទ្រីន Lambda cyhalothrin<br>(22) ភឺមេទ្រីន Permethrin<br>(23) ប្រូហ្វេណូហ្វូស Profenopos<br>(24) ស្ពីណូសាដ Spinosad<br>(25) តេប៊ុយហ្វេណូស៊ីដ bufenocide<br>Others |
| ៧ | ទាកគូ | (1) អាហ្សាឌីរ៉ាកទីន Azadirachtin<br>(2) កាបារីល Carbaryl<br>(3) សាយហ្លូទ្រីន Cyfluthrin<br>(4) សាយភឺមេទ្រីន Cypermethrin<br>(5) ដែតាមេទ្រីន Deltamethrin<br>(6) ឌីយ៉ាហ្ស៊ីណន់ Diazinon<br>(7) ឌីមេតូអែត Dimethoate<br>(8) ឌីណូតេហ្វុយរ៉ាន Dinotefuran<br>(9) អេសហ្វិនវ៉ាឡឺរ៉េត Esfenvalerate<br>(10) ហ្វិនប្រូប៉ាទ្រីន Fenpropathrin<br>(11) អ៊ីមីដាក្លូព្រីត Imidacloprid<br>(12) ឡាំដាសាយហាឡូទ្រីន Lambda cyhalothrin<br>(13) ម៉ាឡាចុង Malathion<br>(14) ភឺមេទ្រីន Permethrin<br>(15) ត្យាមេតូហ្សាម Thiamethoxam<br>Others |

| | | |
|---|---|---|
| ៨ | ជំងឺម៉ូសាអ៊ិច | មិនមាន |
| ៩ | ជំងឺរលួយទន់ | មិនមាន |
| ១០ | ជំងឺអុតកង | (1) ក្លរ៉ូតាឡូនីល Chlorothalonil<br>(2) ម៉ង់កូហ្សែប Mancozeb<br>(3) ប្រូពីណែប Propineb<br>Others |
| ១១ | ជំងឺឫសត្រម៉ោង | មិនមាន |
| ១២ | ជំងឺផ្សិតសំឡី | (1) ក្លរ៉ូតាឡូនីល Chlorothalonil<br>(2) ម៉ង់កូហ្សែប Mancozeb<br>(3) ប្រូពីណែប Propineb<br>(4) ធារ៉ាម Thiram<br>Others |